00890889

**លេខ: D56/4**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**Kingdom of Cambodia**
**Nation Religion King**

**Royaume du Cambodge**
**Nation Religion Roi**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**

**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 28 / 02 / 2013
ម៉ោង (Time/Heure): 16 : 00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Uch Arun

**លេខសំណុំរឿង: ០០៣/០៧-០៩-២០០៩/អ.វ.ត.ក--ក.ស.ច.ស**

ចំពោះមុខ ៖ **ចៅក្រម យូ ប៊ុនឡេង**

**ចៅក្រម Mark Brain HARMON**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៣**

ភាសា ៖ **អង់គ្លេស**

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់បំផុត** **ប្តូរទៅជាសាធារណៈ**

# ដីកាកំណត់កាលបរិច្ឆេទឡើងវិញទាក់ទងនឹងសំណើសុំការតែងតាំងសហមេធាវីដែលត្រូវបានតែងតាំង

**<u>ផ្ញើជូន</u>**

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**សហមេធាវីដែលត្រូវបានតែងតាំង**

លោក អាង ឧត្តម

លោក Michael Karnavas

**<u>ចម្លងជូន</u>**

**អង្គភាពគាំពារការពារក្តី**

លោក Isaac Endeley

1. **បានឃើញ**មាត្រា ២១ នៃកិច្ចព្រមព្រៀងដែលត្រូវបានចុះហត្ថលេខានៅថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២00៣ រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាក្នុងគោលបំណងវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជា និងអន្តរជាតិ ដែលបានប្រព្រឹត្តនៅក្នុងអំឡុងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩("កិច្ចព្រមព្រៀង អ.វ.ត.ក")។

2. **បានឃើញ**ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២00៤ ("ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក")។

3. **បានឃើញ**វិធាន២១ វិធាន២២ វិធាន៥៥ វិធាន៧១ និងវិធាន៧២ នៃវិធានផ្ទៃក្នុងអ.វ.ត.ក ("វិធានផ្ទៃក្នុង")។

4. **បានឃើញ**មាត្រា ៦.២ នៃបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការពារក្តី អ.វ.ត.ក ("បទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការពារក្តី)។

5. **បានឃើញ**ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញាអន្តរជាតិចុះថ្ងៃទី ២0 ខែ វិច្ឆិកា ឆ្នាំ ២00៨ ដែលផ្តួចផ្តើមបង្កើតសំណុំរឿង 00៣ (ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ)[១] ហើយត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងកាលពីថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២00៩[២]។

6. **បានឃើញកិច្ចស៊ើបសួរទាក់ទិននឹងបទចោទអំពីការរំលោភបំពានលើក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាក្រុងហ្សឺណែវ**

---

[១]សំណុំរឿង 00៣/២0-១១-២00៨/អ.វ.ត.ក/ក.ស.ច.ស ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញាទាក់ទងនឹងកងទ័ពបដិវត្តន៍កម្ពុជា ចុះថ្ងៃទី ២0 ខែ វិច្ឆិកា ឆ្នាំ ២00៨ ។

[២]សំណុំរឿង 00៣/២0-១១-២00៨/អ.វ.ត.ក/ក.ស.ច.ស ឯកសារ D1/1 ការជូនដំណឹងអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២00៩ ។

**ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩** ជាបទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៣, ៥, ៦, ២៩(ថ្មី) និង ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា ៥០០, ៥០១, ៥០៣, ៥០៥, ៥០៦, ៥០៧ និង ៥០៨ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ១៩៥៦។

7. បានឃើញសេចក្តីសម្រេចនិងដីកាកំណត់កាលបរិច្ឆេទទាក់ទងនឹងសំណើសុំការតែងតាំងសហមេធាវីដែលត្រូវបានតែងតាំង ជូនដំណឹងនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៣ (D56/3) ("សេចក្តីសម្រេច")

8. បានឃើញការខកខានមិនអនុវត្តតាមសេចក្តីសម្រេចដោយលោកមេធាវី អាង ឧត្តម និងលោកមេធាវី Karnavas ("សហមេធាវីដែលត្រូវបានតែងតាំង")

**អាស្រ័យហេតុនេះ យើងសម្រេច**

9. **បន្តកាលបរិច្ឆេទកំណត់** ដល់សហមេធាវីដែលត្រូវបានតែងតាំង ឱ្យអនុវត្តតាមសេចក្តីសម្រេច នៅក្នុងការបង្ហាញជូនសហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញានូវលិខិតបដិសេធអំពីទំនាស់ផលប្រយោជន៍ដែលពួកគាត់ទទួលបានពី អៀង សារី និងជនសង្ស័យ **រហូតដល់ថ្ងៃច័ន្ទទី០៤ ខែមីនា ឆ្នាំ២០១៣។**

10. **បន្តកាលបរិច្ឆេទកំណត់**ដល់សហមេធាវីដែលត្រូវបានតែងតាំង ឱ្យអនុវត្តតាមសេចក្តីសម្រេច នៅក្នុងការដាក់សារណាស្តីពីលទ្ធភាពមានទំនាស់ផលប្រយោជន៍រវាងតួនាទីរបស់ពួកគាត់ជាសហមេធាវីតំណាង អៀង សារី និងជនសង្ស័យ **រហូតដល់ថ្ងៃច័ន្ទទី០៤ ខែមីណា ឆ្នាំ២០១៣។**

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៣

**Mark Brian Harmon**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
**International Co- Investigating Judge**
**Co-juge d'instruction International**